

និយោជិតដែលធ្វើការនៅទីក្រុង Tacoma ត្រូវបានរ៉ាប់រងដោយស្តង់ដារការងារអប្បបរមាចំនួនពីរ៖

## ច្បាប់ឈប់ស្រមាកព្យាបាលជំងឺទទួលបានប្រាក់កែម្រ

ច្បាប់ឈប់សម្រាកព្យាបាលជំងឺទទួលបានប្រាក់កម្រៃ អនុញ្ញាតឲ្យនិយោជិតឈប់សម្រាកពីការងារសម្រាប់បញ្ហាសុខភាព សុវត្ថិភាព និងការថែទាំគ្រួសារមួយចំនួន ដោយពុំបាត់បង់ប្រាក់កម្រៃ ឬការងាររបស់ខ្លួនឡើយ។ វាក៏ជួយការពារផងដែរនូវសុខភាពសាធារណៈដោយអនុញ្ញាតឲ្យអ្នកធ្វើការងារឈប់សម្រាកនៅផ្ទះនៅពេលដែលពួកគេមានជំងឺ។

## ប្រាក់ឈ្នួលអប្បបរមា

នៅក្នុងខែវិច្ឆិកា ឆ្នាំ 2015 អ្នកបោះឆ្នោតនៅក្រុង Tacoma យល់ព្រមធ្វើការក្នុងកម្រិតប្រាក់ឈ្នួលទាបបំផុតចំនួន 12 ដុល្លារ ក្នុងមួយម៉ោង ដែលរៀបចំអនុវត្តជាដំណាក់កាលក្នុងរយៈពេលជាងពីរឆ្នាំ។

## ការជួយគាំទ្រស្រមាប់កម្មករ

និយោជិតដែលមិនទទួលបានប្រាក់ឈ្នួលអប្បបរមា ឬច្បាប់ឈប់សម្រាកព្យាបាលជំងឺទទួលបានប្រាក់កម្រៃ ត្រូវទំនាក់ទំនងទៅកាន់ទីក្រុង Tacoma។ មិនមានការគិតថ្លៃនោះទេសម្រាប់សេវាស្តង់ដារការងារនានា ហើយការស៊ើបអង្កេតទាំងឡាយពុំមានបញ្ចូលនូវសំណួរទាក់ទងនឹងស្ថានភាពអន្តោប្រវេសន៍នោះទេ។ ដើម្បីស្វែងយល់បន្ថែមអំពីការសម្ងាត់នៅពេលអ្នករាយការណ៍ពីអំពើហិង្សាណាមួយ សូមទូរសព្ទទៅកាន់លេខ (253) 591-5306។

## ការជួយគាំទ្រស្រមាប់អ្នកធ្វើការងារ

ទីក្រុង Tacoma ផ្តល់ជូននូវគំរូនៃការជូនដំណឹងអំពីកន្លែងធ្វើការនានា ការបណ្តុះបណ្តាល ឧបករណ៍សម្រាប់វាយតម្លៃគោលការណ៍ឈប់សម្រាកដោយ ទទួលបានប្រាក់ខែធម្មតា និងដំណឹងដទៃផ្សេងទៀត។ សូមទាក់ទងមកយើងខ្ញុំ ដើម្បីទទួលបានជំនួយដោយផ្ទាល់ ទាក់ទងនឹងសំណួរនានាស្តីពីស្តង់ដាការងារ។

## សូមទាក់ទងមកេយើងខ្ញុំ

**Cityoftacoma.org/employmentstandards**
(253) 591-5306

# ស្តង់ដាការងារ

## ច្បាប់ឈប់សម្រាកព្យាបាលជំងឺទទួលបានប្រាក់កម្រៃនិងប្រាក់ឈ្នួលអប្បបរមានៅទីក្រុង Tacoma



## តើនរណាខ្លះដែលទទួលបានច្បាប់ឈប់ស្រមាកព្យាបាលជំងឺទទួលបានប្រាក់កែម្របស់ទ្រីកុង Tacoma និងប្រាក់ឈ្នួលអប្បបរមា?

ច្បាប់នេះអនុវត្តទៅលើនិយោជិតណាម្នាក់ដែលនឹងត្រូវធ្វើការងារលើសពី 80 ម៉ោងក្នុងអំឡុងឆ្នាំនេះ (រួមមានបុគ្គលិកពេញម៉ោង បុគ្គលិកក្រៅម៉ោង បុគ្គលិកធ្វើការតាមរដូវកាល និងបុគ្គលិកបណ្ដោះអាសន្ន)។

## តើអ្វីទៅជាប្រាក់ឈ្នួលទាបបំផុតនៅទីក្រុង Tacoma?

ប្រាក់ឈ្នួលទាបបំផុតនៅទីក្រុង Tacoma
អនុវត្តជាបន្តបន្ទាប់តាមដំណាក់កាល៖

- 10.35 ដុល្លារ ក្នុងមួយម៉ោង ចាប់ពីដើមខែកុម្ភៈ ឆ្នាំ 2016
- 11.15 ដុល្លារ ក្នុងមួយម៉ោង នៅក្នុងឆ្នាំ 2017
- 12.00 ដុល្លារក្នុងមួយម៉ោងនៅក្នុងឆ្នាំ 2018
- ការកែសម្រួលប្រាក់ឈ្នួលប្រចាំឆ្នាំទៅតាមអតិផរណានឹងចាប់ផ្ដើមក្នុងឆ្នាំ 2019

## តើច្បាប់ឈប់ស្រមាកព្យាបាលជំងឺទទួលបាន្របាក់កែម្រមានចំនួនប៉ុន្មាន?

និយោជិតត្រូវផ្ដល់ជូននូវច្បាប់ឈប់សម្រាករយៈពេលមួយម៉ោងសម្រាប់ការធ្វើការងាររយៈពេល 40 ម៉ោងនៅក្នុងទីក្រុង Tacoma។

## តើមានអ្វីកើតឡើងចំពោះម៉ោងឈប់ស្រមាកព្យាបាលជំងឺទទួលបានប្រាក់កែម្រដែលនិយោជិត្រតូវទទួលបាន ប៉ុន្តែមិនបានប្រើបាស់ក្នុងអំឡុងឆ្នាំនេះ?

និយោជិតអាចបូកយោងបន្តរហូតដល់រយៈពេល 40 ម៉ោងនៃច្បាប់ឈប់សម្រាកព្យាបាលជំងឺទទួលបានប្រាក់កម្រៃដែលមិនទាន់បានប្រើប្រាស់ទៅឆ្នាំបន្ទាប់ទៀតបាន។

## តើនៅពេលដែលអ្នកធ្វើការអាចប្រើប្រាក់ការឈប់ស្រមាកដែលនៅសល់?

និយោជិតអាចប្រើប្រាស់ច្បាប់ឈប់សម្រាកព្យាបាលជំងឺទទួលបានប្រាក់កម្រៃចំនួន 90 ថ្ងៃ បន្ទាប់ពីចាប់ផ្ដើមចូលបម្រើការងារ។

## តើអវត្តមាន្របេភទណាខ្លះដែលត្រូវបានរាប់បញ្ចូលទៅក្នុងច្បាប់ឈប់ស្រមាកព្យាបាលជំងឺទទួលបានប្រាក់កែម្រ?

អ្នកធ្វើការអាចស្នើសុំប្រើប្រាស់ពេលវេលាឈប់សម្រាកដែលទទួលបានដូចខាងក្រោម៖

- ការឈប់សម្រាកទាក់ទងនឹងបញ្ហាសុខភាពផ្លូវកាយនិងផ្លូវចិត្ត
- នៅពេលទីកន្លែងការងារត្រូវបានបិទ តាមរយៈការបង្គាប់បញ្ជាពីមន្ត្រីសាធារណៈ ឬដើម្បីមើលថែទាំកូននៅពេលដែលសាលារៀនត្រូវបានបិទតាមរយៈការបង្គាប់បញ្ជាពីមន្ត្រីសាធារណៈ
- ដើម្បីស្វែងរកកន្លែងសុវត្ថិភាព ឬជំនួយពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ការតាមដាន និង
- សម្រាប់តម្រូវការពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព ឬមរណភាពរបស់សមាជិកគ្រួសារជិតស្និទ្ធ (កូន ចៅ បងប្អូន សហព័ទ្ធ ដៃគូរួមរស់នៅជាមួយគ្នា ឪពុកម្ដាយ ឬជីដូនជីតា)។

## ប្រសិនបើអត្ថប្រយោជន៍ ឬប្រាក់ឈ្នួលនៃការឈប់ស្រមាក់ពីការងារដោយទទួលបានប្រាក់ខេធម្មតារបស់ខ្ញុំលើសពីចំនួនទាំងអស់នេះ តើខ្ញុំត្រូវធ្វើដូចម្ដេច?

ច្បាប់របស់ទីក្រុងបានកំណត់ ស្តង់ដាការងារទាបបំផុតមួយ ហើយច្បាប់ទាំងនោះ មិនមានគោលបំណងក្នុងការរិតបន្តឹង ឬហាមឃាត់គោលការណ៍ឈប់សម្រាកដោយយោគយល់ណាមួយ ឬប្រាក់ឈ្នួលនោះទេ។

## តើខ្ញុំអាចស្វែងយល់បែន្ថមតាមរេបៀបណា?

ទទួលបានព័ត៌មានបន្ថែម សូមចូលទៅកាន់
**cityoftacoma.org/employmentstandards**
ឬ ទូរសព្ទមកយើងខ្ញុំតាមរយៈលេខ (253) 591-5306។

Tacoma